ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុប
## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំឆ្នាំ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ២០២២





ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០២២

# មាតិកា


I- សេចក្តីផ្តើម .......... 1

II- គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០ .......... 5

III- លទ្ធផលជារួម .......... 7

១.ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ .......... 8

២. កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម .......... 9

៣. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម .......... 9

៤.ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម .......... 10

V- លទ្ធផលតាមអនុវិស័យ .......... 10

១.បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច .......... 10

២.ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ .......... 30

៣.លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម .......... 48

៤.លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ .......... 52

៥.លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស .......... 57

VI- បញ្ហាប្រឈម .......... 100

VII- ទិសដៅអនុវត្ត .......... 101

១. ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម .......... 101

២. ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ .......... 103

៣. ផែនការកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ .......... 104

៤. ផែនការជំរុញការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម .......... 105

៥. ផែនការជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ .......... 106

VIII- សេចក្តីសន្និដ្ឋាន .......... 107

តារាងឧបសម្ព័ន្ធ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២១
# និងទិសដៅអនុវត្តឆ្នាំ២០២២

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ហើយវិស័យនេះបាន និងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបន្តជំរុញការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេស ក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិជាសាកលនៃជំងឺឆ្លងកូវីដ-១៩នេះ។

ជាកត្តាសត្យានុម័ត "សន្តិភាព" គឺជាបុរេលក្ខខណ្ឌដ៏ចម្បង និងសំខាន់បំផុតសម្រាប់កសាងខឿនសេដ្ឋកិច្ច និងអភិវឌ្ឍសង្គមជាតិ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវវិធានការគោលនយោបាយនានាសំដៅធានានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលមានភាពអនុគ្រោះសម្រាប់សកម្មភាពផុសផុលនៃការវិនិយោគ និងធុរកិច្ចក្នុងគ្រប់វិស័យ។ សេដ្ឋកិច្ចជាតិបានរីកធំធាត់យ៉ាងឆាប់រហ័ស ហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏កំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។

ក្នុងឆ្នាំ២០២១នេះ ជំងឺកូវីដ-១៩ បានបន្តឆ្លងរាលដាលដល់ស្ទើរគ្រប់ប្រទេស នៅលើសាកលលោក ជាមួយនឹងភាពមិនប្រាកដប្រជាកាន់តែខ្ពស់ តាមរយៈការបំប្លែងខ្លួនជាប្រភេទវីរុសកូវីដ-១៩ថ្មីជាច្រើន ជាពិសេសមេរោគបំប្លែងថ្មី ដែលតា និងអូមីក្រុង ដែលមានលទ្ធភាពចម្លងកាន់តែខ្ពស់ និងអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជនកាន់តែខ្លាំងក្លាជាងមុន។ ជាមួយនឹងបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះ ដើម្បីកាត់បន្ថយករណីឆ្លង និងឈឺធ្ងន់ និងពិសេសសំដៅឈានទៅសម្រេចបានភាពស៊ាំសហគមន៍ ដែលជាកត្តាជំរុញក្នុងការធានានូវការវិលត្រឡប់ឱ្យបានឆាប់រហ័សទៅរក "**ប្រក្រតីភាពថ្មី**" នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ និងកិច្ចដំណើរការនៃសង្គម-សេដ្ឋកិច្ច។

ផ្អែកតាមការវាយតម្លៃ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងអាចមានកំណើនក្នុងអត្រា៤% ដែលជាសញ្ញាមួយទ្រទ្រង់ដល់ការងើបឡើងវិញនៃសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ចក្នុងស្រុក និងកំណើនវិជ្ជមាននៃសេដ្ឋកិច្ចសកល ក៏ដូចជាការកើនឡើងនូវតម្រូវការខាងក្រៅ ពិសេសការប្រើប្រាស់និងការវិនិយោគឯកជន ដែលជាលទ្ធផលនៃ (១).ការដាក់ចេញគោលនយោបាយគាំទ្រនៅតាមបណ្តាប្រទេសនានា (២).ការរំពឹងទុកនៃការងើបឡើងវិញជាបណ្តើរៗ

នៃសកម្មភាពសេដ្ឋកិច្ចដែលជំរុញដោយការចែកចាយ និងការចាក់វ៉ាក់សាំងបានកាន់តែទូលំទូលាយ និង(៣).ការសម្របខ្លួនរបស់ប្រជាជន និងអាជីវកម្មទៅនឹងវិបត្តិជំងឺកូវីដ-១៩។

តាមការវាយតម្លៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**" ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបានអត្រាកំណើនត្រឹមតែ៣%ប៉ុណ្ណោះនៅក្នុងឆ្នាំ២០២១នេះ ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍បាន និងកំពុងបន្ទច់បង្អាក់យ៉ាងខ្លាំងដល់សកម្មភាពពាណិជ្ជកម្ម ដែលធ្វើឱ្យវិស័យទេសចរណ៍ វិស័យលក់ដុំ-លក់រាយ ដែលជាសកម្មភាពប្រើប្រាស់ក្នុងស្រុក វិស័យសំណង់ និងអចលនទ្រព្យបន្តធ្លាក់ចុះយ៉ាងគំហុក។

ដោយឡែក សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងសម្រេចបានក្នុងអត្រា ៥,៦% ដោយសារការសម្របខ្លួនបានទៅនឹង "**ប្រក្រតីភាពថ្មី**" ព្រមទាំងភាពធូរស្រាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបានអនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស ដែលបានជួយជំរុញការងើបឡើងវិញសន្សឹមៗនៃវិស័យ និងអនុវិស័យជំរុញកំណើនសំខាន់ៗ ជាមួយនឹងភាពល្អប្រសើរឡើងវិញនៃកំណើសេដ្ឋកិច្ចសកល និងការងើបឡើងវិញសន្សឹមៗនៃវំហូរមនុស្ស និងវំហូរទុនវិនិយោគ ស្របពេលដែលការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានរំពឹងថានឹងអាចគ្រប់គ្រងបាន។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាក៏បន្តប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅ និងក្នុងប្រទេសផងដែរ ដែលទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាបន្តត្រៀមខ្លួនប្រកបដោយស្មារតីប្រុងប្រយ័ត្ន បុរេសកម្ម និងបត់បែនខ្ពស់ក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍ដើម្បីឆ្លើយតប និងសម្របតាមការវិវឌ្ឍនៃវិបត្តិឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ស្ថិតក្នុងកាលៈទេសៈដែលយើងកំពុងទទួលរងនូវបញ្ហាប្រឈមពីវិបត្តិនៃជំងឺកូវីដ-១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញជាសេនាធិការ បានខិតខំបំពេញកាតព្វកិច្ចចំពោះមុខនេះ សំដៅគាំទ្រ និងចូលរួមដោះស្រាយបញ្ហាជីវភាពប្រជាជនដែលបានជួបប្រទះក្នុងវិបត្តិនេះ និងបានប្រឹងប្រែងយ៉ាងសកម្មថែមទៀត ដើម្បី "ប្រែក្លាយកសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព សំដៅបង្កើនប្រាក់ចំណូលគ្រួសារកសិករ" តាមអភិក្រមប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបយថាផល ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ព្រមទាំងលើកកម្ពស់ពិពិធភាវូបនីយកម្មដំណាំដែលមានសក្តានុពល មានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ជាមួយគ្នានេះដែរ ក្រសួងបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនទៀតរួមមានៈ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការអនុវត្តកសិកម្មតាមកិច្ចសន្យា ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងគោលដៅរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងការបង្កើនចំណូលថវិកាជាតិ។ គួរកត់សម្គាល់ថា ផលិតកម្មដំណាំស្រូវ និងដំណាំកសិឧស្សាហកម្មមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និង

ការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម និងការនាំចេញ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ នៅក្នុងរដូវវស្សាឆ្នាំ២០២១ ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួនសំដៅជំរុញការអភិវឌ្ឍដំណាំស្រូវ ដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដោយលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាព ដើម្បីផ្គត់ផ្គង់តម្រូវការប្រើប្រាស់របស់កសិករ និងទីផ្សារក្នុងស្រុក តាមរយៈការប្រើប្រាស់ពូជដំណាំមានគុណភាព ការធ្វើពិពិធកម្មប្រភេទដំណាំ ការអនុវត្តបង្កុំបច្ចេកទេសទំនើប ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងការផ្តល់សេវាបច្ចេកទេសកសិកម្មថ្មី និងបច្ចេកវិទ្យាវៃឆ្លាតធន់នឹងអាកាសធាតុដល់កសិករ និងសហគមន៍កសិកម្ម ពិសេសការត្រៀមបម្រុងគ្រាប់ពូជដំណាំក្រោមក្របខ័ណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជាសម្រាប់ចែកជូនដល់កសិករ ដើម្បីស្តារផលិតកម្មដំណាំគ្រប់ប្រភេទនៅតាមតំបន់ដែលរងគ្រោះដោយសារកត្តាធម្មជាតិនៅរដូវវស្សា។

ចំពោះអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងបានជំរុញការចិញ្ចឹមសត្វ ទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម សំដៅធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាព សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ដោយបានបំផុស និងលើកទឹកចិត្តដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យបង្កើនផលិតកម្មសត្វប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក្រសួងបានជំរុញក្រុមហ៊ុនចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យបង្កើនទុនវិនិយោគបន្ថែមទៀតក្នុងការពង្រីកកសិដ្ឋានចិញ្ចឹមសត្វ និងបង្កើនផលិតកម្មសត្វព្រមទាំងបានជំរុញឱ្យក្រុមហ៊ុនផលិតចំណីសត្វបង្កើនទុនសម្រាប់ការទិញវត្ថុធាតុដើមក្នុងស្រុក ដើម្បីបង្កើនការផលិតចំណីសត្វ ធានានូវគុណភាព សុវត្ថិភាព និងមានតម្លៃសមស្រប។ ជាមួយគ្នានេះ ក្រសួងបានជំរុញសមាគមចិញ្ចឹមសត្វឱ្យបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល រៀបចំផែនការផលិតកម្មសត្វស្របតាមវិធានជីវសុវត្ថិភាព ឬគោលការណ៍ណែនាំស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ដើម្បីធានាបានការផ្គត់ផ្គង់សត្វ និងសាច់ សម្រាប់បម្រើដល់ការប្រើប្រាស់ក្នុងស្រុក។ ជាងនេះទៅទៀត ដើម្បីការពារផលិតកម្មចិញ្ចឹមជ្រូកក្នុងស្រុក និងរក្សាតម្លៃសមស្របសម្រាប់អ្នកផលិតនិងអ្នកហូបចុក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអនុសាសន៍របស់សម្តេចជាពិសេសក្នុងបរិបទកូវីដ-១៩ បានកំហិតការនាំចូលជ្រូករស់ពីប្រទេសជិតខាង ដែលយុទ្ធសាស្ត្រនេះធ្វើឱ្យការចិញ្ចឹមក្នុងស្រុកបានផុសផុល និងឆ្លើយតបទៅនឹងកង្វះខាតកន្លងមក។

ទន្ទឹមនឹងនេះដែរ ក្រសួងបានបន្តជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រី កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពដល់អ្នកបរិភោគ បង្កើនការផលិតកូនត្រីពូជឱ្យបានគ្រប់គ្រាន់ ដើម្បីចែកចាយដល់កសិករនៅតំបន់ដែលមានសក្តានុពលក្នុងការធ្វើវារីវប្បកម្ម ផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុដល់សហគមន៍នេសាទ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមក្នុងការធ្វើវារីវប្បកម្ម។

ក្រសួងបានបន្តជំរុញឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ធ្វើការណែនាំដល់ប្រជាកសិករ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្មឱ្យត្រៀមលក្ខណៈក្នុងការបង្កបង្កើនផល ដើម្បីបង្កើនផលិតកម្មស្បៀងគ្រប់ប្រភេទប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងត្រូវសម្របសម្រួលសហការជាមួយអាជ្ញាធរមូលដ្ឋាន ពិនិត្យនិងកំណត់តំបន់មានប្រភពទឹក ឬតំបន់ដែលមានស្ថានភាពអំណោយផលនៅក្នុងមូលដ្ឋាន ជាពិសេសសម្របសម្រួលស្វែងរកលទ្ធភាពផ្គត់ផ្គង់ទឹក សម្រាប់ជំរុញផលិតកម្មដំណាំរដូវវស្សាឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ជាមួយគ្នានេះដែរ ក្រសួងបានជំរុញឱ្យមន្ទីរត្រូវធ្វើជាអន្តរការីជំរុញពាណិជ្ជកម្ម និងមានប្រសិទ្ធភាពក្នុងការភ្ជាប់ទំនាក់

ទំនងរវាងអ្នកផលិតជាមួយនឹងអ្នកប្រមូលទិញ តាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីធានាការផ្គត់ផ្គង់ និងថ្លៃកសិផលសមរម្យ។

ពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោង ក្រសួងបានស្នើឱ្យអង្គភាពអនុវត្តគម្រោងអភិវឌ្ឍន៍កសិកម្ម និងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ឱ្យជំរុញការអនុវត្តផែនការសកម្មភាពដែលបានអនុម័តរួច ដើម្បីបង្កើនផលិតកម្មស្បៀងអាហារ (បន្លែ ផ្លែឈើ ត្រី សាច់) សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការហូបចុកក្នុងប្រទេសឱ្យបានគ្រប់គ្រាន់ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩នេះ។

ទាំងនេះគឺបានឆ្លុះបញ្ចាំងឱ្យឃើញថា ស្ថាប័នជាច្រើន ទាំងរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍បាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹងនិងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយកសិករភាគច្រើនបានទទួលយកនូវបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាម និងគំនិតច្នៃប្រឌិតដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើន ទៅតាមអនុវិស័យនីមួយៗ។ ដោយឡែកវិស័យឯកជនបានតម្រង់ទិសការផលិតឆ្ពោះទៅរកទីផ្សារនាំចេញ តាមរយៈការអនុវត្តគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើនសមត្ថភាពកែច្នៃ ធានាបានទាំងគុណភាព និងបរិមាណ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ ពិសេសការនាំចេញអង្ករសរីរាង្គ ចេកអំបូងលឿង ស្វាយកែវរមៀត ម្រេច ដំឡូងមី និងផលិតផលកសិកម្មសំខាន់ៗដទៃទៀតមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងក្នុង ឆ្នាំ២០២១កន្លងទៅនេះ តម្លៃផលិតផលកសិកម្មសរុបមានទំហំ ១៨ ពាន់លានដុល្លារអាមេរិក កើនប្រមាណជាង ៤៣% ធៀបទៅនឹងតម្លៃផលិតផលកសិកម្មសរុបក្នុងឆ្នាំ២០២០ ក្នុងនោះ តម្លៃផលិតផលសរុបផ្នែកដំណាំមានទំហំ ១០,៥ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលសរុបផ្នែកផលិតកម្មសត្វមានទំហំ ៥,១ ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលផ្នែកជលផលមានទំហំ ១,៧ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលផ្នែកព្រៃឈើមានទំហំជាង ៧៨,៦ លានដុល្លារអាមេរិក និងតម្លៃផលិតផលសរុបផ្នែកកៅស៊ូមានទំហំជាង ៦១០លានដុល្លារអាមេរិក។ ដោយឡែក តម្លៃនៃការនាំចេញផលិតផលកសិកម្មសរុបសម្រាប់ឆ្នាំ២០២១ មានទំហំជាង ៥ ពាន់លានដុល្លារអាមេរិក ដែលមានកំណើន ២៥% ធៀបទៅនឹងការនាំផលិតផលកសិកម្មឆ្នាំ២០២០។

ការកែទម្រង់ស៊ីជម្រៅអនុវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព តាមរយៈការអនុវត្តទិសស្លោក **“សហគមន៍នេសាទ គ្មានបទល្មើស”** ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស និងការទាក់ទាញពីភ្ញៀវទេសចរផងដែរ។ ការធ្វើវារីវប្បកម្ម ពិសេសការចិញ្ចឹមបង្កង ត្រីរ៉ស់ ត្រីឆ្តោ និងពពួកត្រីដែលមានតម្លៃទីផ្សារខ្ពស់ ទាំងជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មត្រូវបានអនុវត្តយ៉ាងសកម្ម ហើយបានរួមចំណែកដល់ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

ជាក់ស្តែង នៅដើមខែធ្នូ ឆ្នាំ២០២១ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបំពេញបេសកកម្មជាមួយក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយ ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះមកពិនិត្យ និងចាត់វិធានការបង្ក្រាបការទន្ទ្រានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៅតំបន់បឹងទន្លេសាបស្ថិតក្នុងខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងខេត្តសៀមរាប។ ជាលទ្ធផល ដីព្រៃលិចទឹកជុំវិញបឹងទន្លេសាបត្រូវបានដកហូត ប្រជាពលរដ្ឋចំនួន១៤ ៦៥៦ គ្រួសារ បានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋទំហំ៦១ ១៦១.៧៦ហិកតា និងបានដាំកូនឈើព្រៃលិចទឹកចំនួន៤២ ២៣៥ដើម ឬស្សីចំនួន៨ ៤៤៩ដើម កូនត្នោតចំនួន៣៣៩ដើម និងគ្រាប់ត្នោតចំនួន២៤២ ២០៥គ្រាប់។ ទន្ទឹមនឹងនេះ វិធានការ

មួយចំនួនក៏ត្រូវបានដាក់ឱ្យអនុវត្ត រួមមាន៖ (១). ជូនរដ្ឋបាលខេត្តចេញលិខិតណែនាំដល់អាជ្ញាធរស្រុក ឃុំ បញ្ឈប់ការពិនិត្យបញ្ជាក់លើលិខិតសុំកាន់កាប់ដី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក្នុងដែនព្រៃលិចទឹក ព្រមទាំងចេញលិខិតបដិសេធលើរាល់លិខិតដែលបានចេញរួចពីពេលមុន (២). ចាត់វិធានការបញ្ឈប់ការចូលទន្ទ្រានដីដែនព្រៃលិចទឹកបន្តទៀត ធ្វើអត្តសញ្ញាណអ្នកដែលបានចូលទន្ទ្រានដើម្បីធ្វើការដកហូតដី និងចាត់វិធានការតាមផ្លូវច្បាប់ ដោយត្រូវកសាងអង្គហេតុ និងដាក់បណ្តឹងអាជ្ញាទៅតុលាការ (៣). ទន្ទឹមនឹងវិធានការផ្លូវច្បាប់ ជនល្មើសត្រូវដាំដើមឈើឡើងវិញលើផ្ទៃដីដែលបានទន្ទ្រាន (៤).កងកម្លាំងមានសមត្ថកិច្ច ត្រូវចាត់កម្លាំងចុះល្បាតតាមគោលដៅ ដើម្បីទប់ស្កាត់ការទន្ទ្រានដីព្រៃលិចទឹក និងអនុវត្តវិធានការច្បាប់ (៥). ដាំបង្គោលព្រំដែនព្រៃលិចទឹកដែលខ្វះ និងដែលបានដួលរលំ និងដាក់ពាក្យសុំចុះបញ្ជីដីរដ្ឋនូវដីព្រៃលិចទឹកតំបន់ទន្លេសាប (៦). ចំពោះប្រជាពលរដ្ឋដែលបានដាំដំណាំ ពិសេសដំណាំស្រូវ គឺទុកពេលឱ្យប្រមូលផល រួចស្នើឱ្យធ្វើលិខិតប្រគល់ដីព្រៃលិចទឹកជូនរដ្ឋវិញ (៧). ត្រូវដាំដើមឈើឡើងវិញ និងផ្តល់អាទិភាពលើការដាំដើមឫស្សីក្នុងតំបន់ព្រៃលិចទឹក។

ចំពោះការកែទម្រង់វិស័យព្រៃឈើ ក្រសួងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសពង្រឹងការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ជាការកត់សម្គាល់ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ឃើញថាទទួលបានប្រសិទ្ធភាពជាងមុន។ បន្ថែមលើសពីនេះ ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាខ្លះៗក៏ដោយ ពិសេសការរំខានពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

## II- គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានមហិច្ឆិតាក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ដើម្បីឱ្យវិស័យនេះកាន់តែមានភាពប្រកួតប្រជែង មានបរិយាប័ន្ន និងធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព។

គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០ ត្រូវបានរៀបចំ និងពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដោយបានផ្តល់នូវការតម្រង់ទិសយ៉ាងទូលំទូលាយ និងមុតស្រួច ដើម្បីអភិវឌ្ឍន៍វិស័យនេះ សម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានារួមគ្នាអនុវត្ត។ គោលនយោបាយនេះបានដាក់ចេញនូវផ្នែកសំខាន់ៗចំនួន ៤ គឺ៖ (១) ការធ្វើទំនើបកម្ម និងពាណិជ្ជូបនីយកម្មក្នុងខ្សែច្រវាក់តម្លៃកសិកម្ម (២) ការវិនិយោគសាធារណៈ និងឯកជនក្នុងវិស័យកសិកម្ម (៣) កំណើនប្រកបដោយចីរភាព និងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង (៤) ការកែទម្រង់ស្ថាប័ន និងបញ្ហាអន្តរវិស័យ។

គោលនយោបាយនេះមានគោលបំណងជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែង និងបរិយាប័ន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាហារូបត្ថម្ភ សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក

និងការនាំចេញ ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គោលដៅជាយុទ្ធសាស្ត្រចំនួន ៤ ត្រូវបានកំណត់ និងដាក់ឱ្យអនុវត្ត រួមមាន៖

(ទី១) លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង។

(ទី២) បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ឥណទាន និងការសម្រួលកសិ-ពាណិជ្ជកម្ម។

(ទី៣) បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

(ទី៤) ពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម។

ចំណុចសំខាន់នៃគោលនយោបាយនេះ គឺផ្តោតលើយុទ្ធសាស្ត្របង្កើនផលិតភាព និងជំរុញកំណើនកសិកម្ម សំដៅពង្រីកការនាំចេញផលិតផលកសិកម្ម ព្រមទាំងការសម្របសម្រួល និងការផ្លាស់ប្តូរទៅជាប្រព័ន្ធស្បៀងអាហារទំនើប និងប្រកបដោយនិរន្តរភាព។ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មត្រូវបានសម្រួលឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាឆ្នាំ២០៣០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រប្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ក៏នឹងត្រូវបានរៀបចំជាបន្តទៀត ដោយត្រូវបង្ហាញយ៉ាងលម្អិត និងជាក់លាក់នូវសកម្មភាពគោលនយោបាយសម្រាប់អនុវត្ត។

យុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើ គឺផ្តោតសំខាន់លើការរៀបចំ និងការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាក់លាក់មួយ ដោយផ្អែកលើយន្តការសហការជិតស្និទ្ធ និងសម្របសម្រួលដើម្បីធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ ប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មត្រូវការថវិកាពីប្រភពសំខាន់បីគឺ ថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍន៍ និងការវិនិយោគរបស់វិស័យឯកជន។ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវបន្តដាក់ចេញនូវកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពអាទិភាពសំខាន់ៗ សំដៅធ្វើការវិភាជន៍ថវិកាជាតិ និងថវិកាដែលបានមកពីដៃគូអភិវឌ្ឍន៍ឱ្យបានសមស្រប ឆ្លើយតបទៅនឹងសូចនាករកំណត់ក្នុងគោលនយោបាយនេះ។ ជាមួយគ្នានេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធត្រូវបង្កើតគម្រោងលម្អិតដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ (PIP) ផែនការរំកិលបីឆ្នាំ ដោយអនុលោមតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយជោគជ័យ ក៏នឹងអាស្រ័យលើស្ថានការណ៍ក្នុងតំបន់ និងពិភពលោក ក៏ដូចជាសភាពការណ៍ក្នុងប្រទេស ដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅលើដំណើរការនៃការធ្វើទំនើបកម្មកសិកម្ម ការប្រកួតប្រជែងកសិ-ពាណិជ្ជកម្ម ផលិតភាពនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី និងកម្រិតនៃការវិនិយោគឯកជន។ ក្របខ័ណ្ឌនៃយន្តការពិនិត្យតាមដាន និងវាយតម្លៃនឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៅក្នុងកិច្ចការនេះ។ ការប្តេជ្ញាយ៉ាងមុតមាំក្នុងការសម្របសម្រួល និងអនុវត្តគឺជាមូលដ្ឋាននៃជោគជ័យ ដោយត្រូវប្រែក្លាយផែនការសកម្មភាពជាលក្ខណៈគោលនយោបាយដែលមានក្នុងគោលនយោបាយនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើន និងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យគ្រប់តួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តគោលនយោបាយនេះឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

## III- **លទ្ធផលជារួម**

នៅក្នុងឆ្នាំ២០២១នេះ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានកូនរដូវប្រាំងកើតឡើងនៅតាមបណ្តាខេត្តមួយចំនួន ពិសេសមានគ្រោះរាំងស្ងួតក្នុងអំឡុងខែសីហានិងដើមខែកញ្ញា និងជាចុងក្រោយគឺគ្រោះទឹកជំនន់បានកើតមានក្នុងអំឡុងខែតុលា ដែលបានបង្កការលំបាកដល់ដំណើរការបង្កបង្កើនផលដំណាំ។

មកទល់ពេលនេះ ជំងឺកូវីដ-១៩ បាននិងកំពុងរីករាលដាលនៅទូទាំងសកលលោក និងបានធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយនឹងការខិតខំស្តារឡើងវិញនូវវិស័យបម្រើឱ្យសេដ្ឋកិច្ច វិស័យកសិកម្មបានឈរនៅក្នុងអាទិភាពមួយខ្ពស់ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ពិសេសពាក់ព័ន្ធនឹងការបង្កើនស្បៀងអាហារ អង្ករ ត្រីសាច់ឱ្យបានគ្រប់គ្រាន់ និងនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ផ្អែកលើកត្តាសត្យានុម័តនិងអត្តនោម័ត និងអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើវិធានការត្រៀមបម្រុងស្បៀងអាហារសម្រាប់ប្រជាពលរដ្ឋ ក្នុងស្ថានភាពដែលមានផលប៉ះពាល់ជាសកលបង្កដោយជំងឺកូវីដ-១៩ ការជំរុញអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបានវាយតម្លៃថាបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងបរិកាណ៌នេះ យុទ្ធនាការជាទ្រង់ទ្រាយធំក្នុងការបំផុសប្រជាកសិករនៅតាមមូលដ្ឋាន ដែលមានសក្តានុពលផលិតកម្មកសិកម្ម ឱ្យធ្វើការដាំដុះដំណាំស្បៀង ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ស្របតាមវិធានការបច្ចេកទេសកសិកម្មទំនើបត្រូវបានរៀបចំធ្វើយ៉ាងផុលផុស។ ជាមួយគ្នានេះ សន្ទុះនៃការអនុវត្តផែនការសកម្មភាពចាំបាច់ក្នុងស្ថានភាពបន្ទាន់ជាការឆ្លើយតប ដើម្បីបង្កើនផលិតកម្មស្បៀងប្រកបដោយគុណភាព និងសុវត្ថិភាព សំដៅរួមចំណែកបង្កើននូវឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជាពលករដែលបានត្រឡប់ពីបរទេសវិញ ក៏ត្រូវបានអនុវត្តយ៉ាងល្អប្រសើរ។ ម៉្យាងវិញទៀត សកម្មភាពឆ្លើយតបបន្ទាន់ក្នុងបណ្តាគម្រោងដែលកំពុងអនុវត្តក៏ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដើម្បីរួមចំណែកជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ ពិសេសបញ្ហាទឹកដោយការប្រើប្រព័ន្ធសន្សំសំចៃទឹក ការជួយជីកនិងស្តារស្រះ ត្រពាំង និងអណ្តូងជាដើម ការអប់រំបណ្តុះបណ្តាលកសិករ ណែនាំផ្សព្វផ្សាយអំពីបច្ចេកទេស ការអនុវត្តកសិកម្មល្អ និងការធ្វើហិរញ្ញប្បទានដល់ប្រជាកសិករតាមគ្រប់រូបភាព សំដៅដល់ការបង្កើតកសិដ្ឋានថ្មីៗ ព្រមទាំងគាំទ្រ និងពង្រីកទំហំផលិតកម្មស្បៀងដែលឆាប់ផ្តល់ផល។ល។

លើសពីនេះទៀត ការចិញ្ចឹមសត្វដើម្បីធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វ សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ត្រូវបានវាយតម្លៃថាអនុវត្តបានល្អប្រសើរជាមួយនឹងការរៀបចំយុទ្ធនាការបំផុសដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ឱ្យបង្កើនការចិញ្ចឹមសត្វដែលមានវដ្តផលិតកម្មខ្លី និងដោះស្រាយបានទាន់ពេលវេលា បញ្ហាសន្តិសុខស្បៀងត្រូវបានធ្វើយ៉ាងយកចិត្តទុកដាក់ខ្ពស់។ បន្ថែមពីនេះ ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វថ្មីៗរបស់កសិករត្រូវបានពិនិត្យឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់ និងក្រុមហ៊ុនឯកជនក៏ត្រូវបានជំរុញឱ្យមានការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំបន្ថែមទៀត ដើម្បីបម្រើសេចក្តីត្រូវការសាច់ក្នុងប្រទេស និងកាត់បន្ថយការនាំចូល។

ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រីសម្រាប់ប្រើប្រាស់ក្នុងស្រុក រក្សាបានតុល្យភាពតម្លៃទីផ្សារ ដែលរួមចំណែកធានាបាននូវសន្តិសុខស្បៀងគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋកម្ពុជា រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានធ្វើយុទ្ធនាការទ្រង់ទ្រាយធំក្នុងការចុះជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍ ព្រមទាំងបានលើកទឹកចិត្តដល់ការចិញ្ចឹមត្រីដែលមានវដ្តផលិតកម្មខ្លី ដូចជាការចិញ្ចឹមត្រីអណ្តែង កង្កែបនៅក្នុងតង់ផ្លាស្ទិក និងប្រភេទត្រីមួយចំនួនទៀតដែលមិនប្រើទុនវិនិយោគច្រើន ទីតាំងធំ និងទឹកច្រើន តែផ្តល់នូវផលល្អនិងឆាប់រហ័ស។

គ្រប់អង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់នូវធនធានដែលទទួលបានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងការបង្កើនយុទ្ធនាការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មនេះ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្ម ទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

## ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

ក្នុងឆ្នាំ២០២១នេះ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៤,៤% (គិតតាមថ្លៃបច្ចុប្បន្ន) នៃផលិតផលសរុបក្នុងស្រុក។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣៨,៥% និងវិស័យសេវាកម្មប្រមាណ៣៧%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលថយចុះពី២៤,៩% ដល់២៤,៤% ក្នុងចន្លោះឆ្នាំ២០១៧-២០២១។

**ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២១

ទោះជាការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ យ៉ាងនេះក្តី ក៏តម្លៃបន្ថែមសរុប (គិតតាមតម្លៃបច្ចុប្បន្ន) នៃវិស័យកសិកម្ម (Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៨ ៩៩៩ ពាន់លានរៀលនៅឆ្នាំ២០១២ ដល់ ២០ ៩៨៦ពាន់លានរៀលនៅឆ្នាំ២០១៧ និងបានបន្តកើនដល់ ២៤ ៧៥៥ពាន់លានរៀលនៅឆ្នាំ២០២១។